- រៀបកញ្ចេជាថ្នាក់ៗ ហើយជៀសវាងការអង្គុយលើ ឬដាក់អ្វីធ្ងន់ពីលើនាំឱ្យបាក់បែក ឬក្តៅហាប់រលួយ
- ខេងត្រូវរៀបជាថ្នាក់ៗ ដោយមានឈើកល់
- ត្រូវគ្របខេងនឹងក្រណាត់សើមការពារធូលី។





## ៥) <u>ការស្តុកទុក</u>

ស្ពៃជ្រក់អាចទុកបាន ១ យប់ ២ ថ្ងៃ ដោយគេធ្វើការសំដិលវានៅលើគ្រែ នៅពេលយប់ទុកវាហាលសន្សើម និងពេលថ្ងៃយកចូលម្លប់។ បើសិនជាទុករយៈពេល ២ យប់ អាចបាត់បង់រហូតដល់ ៣៥% តែវាអាចយកទៅធ្វើជ្រក់បាន។ ដាក់សំដិលកន្លែងម្លប់ ហើយពេលយប់អាចដាក់ឱ្យត្រូវសន្សើមបាន តែមិនឱ្យត្រូវថ្ងៃទេ។ នៅពេលដែលយើងស្តុកទុកអាចប្រើប្រាស់កំបោរ ឬសាច់ជូរលាបគល់របស់វាដើម្បីឱ្យអាចរក្សាទុកបានយូរ។



---

**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

ស៊ី សុង ម៉ៅ ចិញ និង វិញ ស៊ាម

# វិធីសាស្ត្រគ្រប់គ្រង
# ស្ពៃជ្រក់
## ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ចំពោះដំណាំស្ពៃ គេអាចប្រមូលផលនៅពេលដែលគេសង្កេតឃើញថា ៖

- មានស្រទាប់ម្សៅស្ថិតនៅលើធាងផ្នែកគល់របស់វា
- វាពេញអាយុល្អ គឺពី ២ ខែទៅ ២ ខែកន្លះ
- ប្រមូលផលនៅពេលដែលមេឃត្រជាក់ ហើយស្ងួតសំណើម ព្រោះធាងរបស់វាស្រួយណាស់នៅពេលមេឃត្រជាក់ (ពេលព្រឹកចាប់ពីម៉ោង ៩ និងពេលរសៀលចាប់ពីម៉ោង ៣)។ ក្នុងការប្រមូលផល គឺគេកាត់ ដោយប្រើកូនកាំបិតដែលមុតល្អ
- ពេលកាត់ត្រូវប្រុងប្រយ័ត្ន ជៀសវាងការប៉ះទង្គិចខ្លាំង។



- ត្រូវប្រមូលស្ពៃជ្រក់ចូលក្នុងម្លប់ភ្លាមៗ បន្ទាប់ពីកាត់ហើយ ជៀសវាងកុំឱ្យវាត្រូវកំដៅថ្ងៃ

## ២) ការសំអាត

- ក្រោយពេលប្រមូលផលរួច គេមិនលាងសំអាតដោយទឹកទេ ព្រោះវាអាចបៀមទឹក និងធ្វើឱ្យស្ពៃឆាប់ជាំ និងងាយរលួយ។ គេគ្រាន់តែកាត់ស្លឹកដែលចាស់ៗចោលតែប៉ុណ្ណោះ
- រួចដាក់សំដិលក្រោមម្លប់រយៈពេលពី ៣០ នាទី ដោយយោងទៅតាមអាកាសធាតុក្តៅ ឬត្រជាក់
- កុំឱ្យស្រពោនពេក តែច្របាច់ទៅមិនបាក់
- ត្រូវបេះស្លឹករលួយចេញដើម្បីកុំឱ្យឆ្លង។



## ៣) ការជ្រើសរើស ឬវេចខ្ចប់

បន្ទាប់ពីសំដិលរួច គេតំរៀបចូលទៅក្នុងខេងដែកកញ្ជេដែលមានរុំបាវ ឬដាក់លើរ៉ឺម៉ក ឬឡានតែម្តង ដោយមានទ្រាប់ និងគ្របពីលើដោយប្រើស្លឹកស្រស់ (ស្លឹកចេកស្រស់)។ ការតំរៀប គឺដាក់គល់ស្ពៃចេញក្រៅ ហើយជារង្វង់ បើដាក់ក្នុងកញ្ជេ។ កុំដាក់ឱ្យវាពេញហួសមាត់កញ្ជេ។





## ៤) ការដឹកជញ្ជូន

- ការដឹកជញ្ជូន គឺគេអាចដឹកបាននៅពេលព្រឹក រសៀល និងពេលយប់ ដោយម៉ូតូរ៉ឺម៉ក ឬឡាន ទៅកាន់ទីផ្សារ